ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Cambodian Rubber Research Institute

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២១ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា








# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២១
# របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ថ្ងៃ សុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (*វ.ស.ក.ក*) មានកិត្តិយសក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពការងារស្រាវជ្រាវប្រចាំឆ្នាំ២០២១ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះបង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់ការិយាល័យមានដូចជា (១) ការិយាល័យបង្កាត់ពូជ (២)ការិយាល័យដាំដុះនិងការពារ (៣)ការិយាល័យសរីរវិទ្យានិងអាជីវកម្ម (៤)មន្ទីរពិសោធន៍ជាតិយថាប្រភេទ (៥)ស្ថានីយអនុវត្ត ព្រមទាំងការិយាល័យពាក់ព័ន្ធមួយចំនួនទៀតក្រោមឱវាទ *វ.ស.ក.ក*។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារ កិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិត និងថ្នាក់ដឹកនាំ *វ.ស.ក.ក* ទាំងអស់នៅក្នុងការពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្តាដៃគូអន្តរជាតិផ្សេងទៀតមានដូចជា៖ មជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិដើម្បីអភិវឌ្ឍកសិកម្ម (CIRAD), ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ(IRRDB), ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD), បណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(CATAS), វេទិកាដៃគូស្រាវជ្រាវកៅស៊ូ(HRPP), អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ(WWF) ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចីរភាព។

ខ្ញុំសង្ឃឹមថា ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូនឹងទទួលបាននូវព័ត៌មានផ្សេងៗពីការពិសោធស្រាវជ្រាវដំណាំកៅស៊ូតាមរយៈរបាយការណ៍នេះ ព្រមទាំងចូលរួមសហការ ផ្តល់នូវមតិគាំទ្រ កែលម្អ និងតម្រង់ទិសការងារពិសោធស្រាវជ្រាវ ហើយនិងការរៀបចំនូវរបាយការណ៍សកម្មភាពនេះឲ្យមានលក្ខណៈកាន់តែប្រសើរឡើង។

ថ្ងៃ សុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

**នាយក**
**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

**លិម ខាន់ទីវ៉ា**

# មាតិកា

ទំព័រ


អារម្ភកថា ......... ii

១. សេចក្តីផ្តើម ......... 1

២. អង្គការលេខ និងស្ថានភាពបុគ្គលិក ......... 2

២.១. អង្គការលេខ ......... 2

២.២. ស្ថានភាពបុគ្គលិក ......... 3

៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក ......... 4

៣.១. ផ្នែកក្សេត្រសាស្ត្រ ......... 4

៣.១.១. ការិយាល័យបង្កាត់ពូជ ......... 4

៣.១.២. ការិយាល័យដាំដុះ និងការពារ ......... 6

៣.១.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម ......... 9

៣.២. មន្ទីរពិសោធន៍ជាតិយថាប្រភេទ ......... 12

៣.៣. ស្ថានីយ៍អនុវត្ត ......... 16

៣.៤. ការបណ្តុះបណ្តាលនិងផ្ទេរបច្ចេកវិទ្យា ......... 17

៣.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ......... 17

៣.៦. ការអនុវត្តថវិកាកម្មវិធី ......... 18

៣.៦.១. ចង្កោមសកម្មភាពទី១ ការអភិវក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ ......... 19

៣.៦.២.ចង្កោមសកម្មភាពទី២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ ......... 19

៣.៦.៣.ចង្កោមសកម្មភាពទី៣ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការ និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ ......... 20

៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ......... 20

៥. ទិសដៅការងារឆ្នាំ២០២២ និងសន្និដ្ឋាន ......... 21

៥.១. ទិសដៅការងារឆ្នាំ២០២២ ......... 21

៥.២. សេចក្តីសន្និដ្ឋាន ......... 21

៦. កម្រងរូបភាព និងសកម្មភាពការងារ ......... 22

## ១. សេចក្តីផ្តើម

កៅស៊ូធម្មជាតិជាដំណាំសេដ្ឋកិច្ច និងយុទ្ធសាស្ត្រយ៉ាងសំខាន់ ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើន លើសលប់ដល់អ្នកដាំ ផ្តល់ជាចំណូលដល់សេដ្ឋកិច្ចជាតិនិងសង្គម ព្រមទាំងបរិស្ថាន។ ជាការឆ្លើយតបទៅនឹង គោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្ម នៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណត្តិទី៦ ផែនការ សកម្មភាពជាតិ ស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា២០១៦-២០២៥ និងផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្រសួងកសិកម្មបានលើកឡើងនូវផែនការយុទ្ធសាស្ត្រ អភិវឌ្ឍវិស័យកសិកម្ម ២០១៩-២០២៣ ទិសដៅគោលនយោបាយរួមសំដៅ ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យ បានក្នុងរង្វង់៤%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកំពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្ម តាមកិច្ចសន្យានិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។ ក្នុងបរិបទ នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ ក្នុងនោះ **វ.ស.ក.ក** ស្ថិត នៅក្នុងកម្មវិធី ទី១ គឺ៖ បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច។ **វ.ស.ក.ក** ជាអង្គភាពគ្រឹះស្ថាន សាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាល ផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំ តម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ **វ.ស.ក.ក** ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធី ទី១ និងអនុកម្មវិធីទី៦ ស្តីអំពី៖ «**លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ** » ដែលក្នុងនោះមាន ចង្កោមសកម្មភាពចំនួន៣ គឺ៖ ***១.៦.១.*** **ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុង ការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ** ***១.៦.២.*** **ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយ ប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ** ***១.៦.៣.*** **ទទួលធ្វើសវនកម្មផ្ទៃក្នុង និងក្រៅពីការិយាល័យស្តាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។**

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗរបស់ **វ.ស.ក.ក** ឆ្លើយតបទៅនឹងគោលនយាបាយនិង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៩-២០២៣ ហើយនិងផែនការ រយៈពេលខ្លី មធ្យម និងវែងរបស់ **វ.ស.ក.ក** ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធី ដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែមទៀត បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ ហើយនិងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

# ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

## ២.១. អង្គការលេខ




**យោង៖** -អនុក្រឹត្យលេខ៦៩អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-អនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៩ ចំណុច៩.១ នៃអនុក្រឹត្យលេខ៦៩អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧

*វ.ស.ក.ក* ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារដូចតទៅ៖ *វ.ស.ក.ក* មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញ ផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ *វ.ស.ក.ក* បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូ សំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជាដែលមានសក្តានុពល បន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ក្នុងឆ្នាំ ២០២១នេះ *វ.ស.ក.ក* បានអនុវត្តនិងបន្តការងារស្រាវជ្រាវ ហើយនិងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ ដែលជាសរុបមាន៦២ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ *វ.ស.ក.ក* បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្ស តាមរយៈការបង្ហាត់បង្រៀននិស្សិត នៅតាមគ្រឹះស្ថានសិក្សានិងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍និងការដឹកនាំសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។ នៅក្នុងអនុក្រឹត្យ *វ.ស.ក.ក* មានកាតព្វកិច្ចចំនួន៨ ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើង សំដៅលើការអនុវត្តឲ្យបានសម្រេចឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ *វ.ស.ក.ក* តាមរយៈប្រកាសលេខ៥៧៦ ប្រក.កសក.ប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ *វ.ស.ក.ក* មានការិយាល័យ និងអង្គភាពចំណុះចំនួន៧ រួមមាន៖

១- ការិយាល័យ រដ្ឋបាល និងបុគ្គលិក
២- ការិយាល័យ ផែនការ និងគណនេយ្យ
៣- ការិយាល័យ បង្កាត់ពូជ
៤- ការិយាល័យ ដាំដុះ និងការពារ
៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម
៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ
៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

## ២.២ ស្ថានភាពបុគ្គលិក

មន្ត្រី *វ.ស.ក.ក* ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤៨នាក់ ក្នុងនោះមានស្ត្រី១២នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប២៨៥នាក់។ មន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៨នាក់មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ០៩នាក់ |
| + បរិញ្ញាបត្រ | ៣៣នាក់ |
| + បរិញ្ញាបត្ររង | ០៣នាក់ |

+ បបមឯកទេស ០២នាក់

និងមន្ត្រីជាប់កិច្ចសន្យា ២០នាក់

## ៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក

ការបំពេញភារកិច្ចក្នុងឆ្នាំ២០២១ ក៏ដូចបណ្តាឆ្នាំមុនៗកន្លងមកដែរ **វ.ស.ក.ក** បានខិតខំបន្តអនុវត្តការងារពិសោធន៍ និងស្រាវជ្រាវឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត **វ.ស.ក.ក** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

### ៣.១. ផ្នែកក្សេត្រសាស្ត្រ

#### ៣.១.១. ការិយាល័យបង្កាត់ពូជ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- បានតាមដានស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ចំនួន២៣ចម្ការពិសោធន៍ ដែលបានដាំរាយប៉ាយទៅតាមទីតាំង និងតំបន់ផ្សេងៗដូចជា (១) ស្ថានីយ៍អនុវត្តនៃ វ.ស.ក.ក. (២) ក្រុមហ៊ុនសុភ័ក្តនិកា (៣) ក្រុមហ៊ុនក្រែក ខេមបូឌា (ខេត្តត្បូងឃ្មុំ) (៤) ក្រុមហ៊ុនទ្រីភាព ទន្លេម្រេច (ខេត្ត ព្រះវិហារ) (៥) ក្រុមហ៊ុន SOCFINKCD (ខេត្តមណ្ឌលគីរី)
- ការស្រាវជ្រាវការអភិវឌ្ឍធនធានក្លូនកៅស៊ូកម្ពុជា ធនធានសេនេទិច(genotype)កៅស៊ូលេចធ្លោចំនួន២០ត្រូវបានជ្រើសរើសនិងបានដាំនៅចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយតូច ដោយធ្វើការប្រៀបជាមួយបណ្តាក្លូនកស្សិណរួមមាន GT1, PB 260, RRIM 600 និង PB 217។ សេណូទីបចំនួន១២បានបង្ហាញអំពីការលូតលាស់ ទិន្នផល និងលក្ខណៈសរីរទឹកជ័រ(Suc, R-SH, Thiol…) ល្អជាងបណ្តាក្លូន កស្សិណ ហើយក្នុងនោះមានសេណូទីបចំនួន២បានបង្ហាញពីភាពល្អដាច់គេក្នុងចំណោមសេណូទីបទាំង១២។ នេះបញ្ជាក់ថាសេណូទីបទាំងនោះជាក្តីរំពឹងក្នុងការបង្កើត និងទទួលបានក្លូនកៅស៊ូកម្ពុជាដ៏ល្អនាពេលអនាគត
- ថែទាំច្បារបង្កាត់ពូជ និងអង្កេតការជ្រុះស្លឹក និងចេញផ្ការលើក្លូនកៅស៊ូចំនួន១៦
- បានអនុវត្តការថែទាំច្បារពូជកៅស៊ូទំហំ៨,៦០ហិកតាសម្រាប់បំរើដល់ការពិសោធស្រាវជ្រាវ
- ដាំពង្រីកកូនកៅស៊ូនៅក្នុងច្បារពូជសរុបបានចំនួន៧៧៩កូន(ក្លូនទទួលពី CATAS)
- សហការជាមួយអង្គការ WWF-កម្ពុជា ក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រនិងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី
- មន្ត្រីការិយាល័យមួយរូបបានទៅបង្រៀននិស្សិតនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- ចុះបេសកកម្មស្រង់ទិន្នន័យមាឌឈើតាមក្លូននីមួយៗនៃចម្ការពិសោធន៍ក្លូន KR.AA.01 និងKR.AA.02 នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក ខេមបូឌា ខេត្តត្បូងឃ្មុំ
- ដឹកនាំនិស្សិតពីររូប (មួយរូបមកពីសកលវិទ្យាល័យភូមិន្ទកសិកម្ម និងមួយរូបទៀតមកពីវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម) ដើម្បីសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ
- ចុះត្រួតពិនិត្យចម្ការបង្ហាញលើការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី
- ប្រជុំពិភាក្សាការងារជាមួយជំនាញការ CIRAD អំពីការងារស្រាវជ្រាវ
- អមដំណើរប្រតិភូមកពី AFD និង CIRAD ក្នុងការចុះត្រួតពិនិត្យចម្ការពិសោធន៍ និងការងារស្រាវជ្រាវនៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

# សកម្មភាពការងាររបស់ការិយាល័យបង្កាត់ពូជ



សកម្មភាពវាស់ទំហំដើមកៅស៊ូតាមក្លូននីមួយៗ



សកម្មភាពការថែទាំច្បារពូជកៅស៊ូ





សកម្មភាពនៃការចុះជ្រើសរើសចម្ការកៅស៊ូគ្រួសារដើម្បីរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អ
លើការយកផលទឹកជ័រនិងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័រ
របស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី





សកម្មភាពប្រមូលទិន្នន័យជ័រពិសោធន៍

### ៣.១.២. ការិយាល័យដាំដុះ និងការពារ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- បានតាមដាន ស្រង់បញ្ចូលនិងវិភាគទិន្នន័យចម្ការពិសោធន៍រួមមាន៖ (១) អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (២) ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ផ្តល់ផល និងកៅស៊ូផ្តល់ផល (៣) ការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ (៤)ដំណាំគម្របដី ផលិតកម្មជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (៥)ទំនាក់ទំនងរវាងការលូតលាស់ និងទិន្នផល ទៅនឹងអាកាសធាតុ ហើយនិងចង្វាក់ចៀរជ័រ d3, d4 (៦) ដង់ស៊ីតេដាំដុះដើមកៅស៊ូ (៧) ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់និងទិន្នផលកៅស៊ូ។
- បានអនុវត្តការងារដាំដុះកូនកៅស៊ូក្នុងឆ្នាំ២០២១ លើផ្ទៃដី ៩,៥០ហិកតា
- បានប្រមូលផលដំណាំគម្របដី Pueraria Phaseoloides នៅចម្ការពិសោធន៍ ប្លុក42 BNW ដាំឆ្នាំ២០១៨
- រៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២១-២០២២ លើផ្ទៃដី០,៣៥ហិកតា
- អនុវត្តការថែទាំកៅស៊ូគ្រប់ចម្ការពិសោធន៍ (កាត់ខ្នែងកូនកៅស៊ូ ភ្ជួរដីចន្លោះរង ជំរះរើករង )
- អនុវត្តការដាំជួសកូនកៅស៊ូងាប់ (កៅស៊ូដាំឆ្នាំ ២០១៩-២០២១)
- បានអនុវត្តការដាក់ជីបំប៉នលើកូនកៅស៊ូមិនទាន់ផ្តល់ផលចំនួនពីរលើកលើផ្ទៃដី៣៧,៧៥ហិកតា និងចម្ការពិសោធន៍ជីលើកៅស៊ូផ្តល់ផលចំនួន៤ចម្ការលើផ្ទៃដី១៥,២០ហិកតា
- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្សិតនៅតាមប្រគៀបមែកកៅស៊ូដែលមានអាយុពី ៤-១០ឆ្នាំ លើផ្ទៃដី ១៦១,៦៦ហិកតា
- អនុវត្តការថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនកៅស៊ូ ឆ្នាំ២០២១-២០២២ (ជំរះស្មៅ បាញ់ថ្នាំ Dithan M45 ការពារនិងព្យាបាលជំងឺស្លឹក និងដាក់ជីបំប៉នលើកទី៣)



ការដាំដុះ និងដាក់ជី ដំណាំគម្របដីចន្លោះរងកៅស៊ូ

# សកម្មភាពការងាររបស់ការិយាល័យដាំដុះ និងការពារ




សកម្មភាពការដាក់គ្រាប់កៅស៊ូចូលក្នុងថង់ដើម្បីរៀបចំថ្នាល់បណ្តុះ



សកម្មភាពថែទាំកូនកៅស៊ូ



សកម្មភាពការដាក់ជីលាមកសត្វក្នុងរណ្តៅកូនកៅស៊ូ



សកម្មភាពបំបៅកូនកៅស៊ូ



សកម្មភាពដាក់ជីកូនកៅស៊ូនៅថ្នាលបណ្តុះកូន

# សកម្មភាពការងាររបស់ការិយាល័យដាំដុះ និងការពារ



សកម្មភាពការកាត់ស្មៅតាមរងកៅស៊ូនៅចម្ការ
កៅស៊ូដាំឆ្នាំ២០២១



សកម្មភាពការបោះបង្គោលតំរុយសម្រាប់ការដាំកូន
កៅស៊ូថ្មី



សកម្មភាពត្រាក់ទ័រខួងរណ្តៅចម្ការសម្រាប់ការដាំដុះ



សកម្មភាពការដាក់ជីលាមកសត្វនៅក្នុងរណ្តៅកូន
កៅស៊ូ





សកម្មភាពបាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបបំបាត់ជំងឺផ្កាកុលាប នៅលើមែកកៅស៊ូ

### ៣.១.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម

សកម្មភាពការងារ និងលទ្ធផលការងារចម្ការពិសោធន៍ដែលបានអនុវត្តរួមមាន៖

- តាមដាន ស្រង់ បញ្ចូលទិន្នន័យចម្ការពិសោធន៍នៅក្នុងស្ថានីយ៍ចំនួន១៣និងក្រៅស្ថានីយចំនួន១ចម្ការពិសោធន៍រួមមាន៖ (១) សក្តានុពលទិន្នផល(d3, d4) និងប្រព័ន្ធចង្វាក់ចៀររង្វើល(d4, d5, d6)(២)ការបើកមុខចៀរលើទំហំដើមខុសគ្នា (៣)ប្រសិទ្ធភាពនៃរបាំងការពារទឹកភ្លៀង
- ស្រង់ទិន្នន័យជំងឺស្ងួតមុខចៀរ (TPD) នៅចម្ការពិសោធន៍ IR.AE.02, IR.AE.03, IR.AE.05, IR.AE.06, IR.AE.08, IR.AE.09, IR.AE.10, IR.AE.13, IR.AE.17, IR.AE.18 និង KR.AE.03
- ផ្ទៀងផ្ទាត់ (Calibrate) ឧបករណ៍ ជញ្ជីងអេឡិចត្រូនិច ពីប៉ែតអូតូម៉ាទិច និង pH ម៉ែត្រ
- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)
- យកសំណាក និងវិភាគសរីរទឹកជ័រ (Latex diagnosis) ចម្ការពិសោធន៍ក្នុង និងក្រៅស្ថានីយចំនួន២៩ ស្មើនឹង ១២៨០សំណាក
- បង្កើតចម្ការពិសោធន៍ថ្មីឥទ្ធិពលនៃការបើកមុខចៀរនៅទំហំដើមខុសៗគ្នា
- ដឹកនាំនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួនមួយរូប ដើម្បីសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ
- បណ្តុះបណ្តាលនិស្សិតសាលាជាតិកសិកម្មកំពង់ចាម ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រដំណាំកៅស៊ូ លើមុខវិជ្ជា ការវិភាគសរីរសាស្ត្រទឹកជ័រ និងការប្រមូលផលជ័រកៅស៊ូ
- សហការជាមួយអង្គការ WWF និងអគ្គនាយកដ្ឋានកៅស៊ូ រៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅ ខេត្តមណ្ឌលគិរី
- ចូលរួមរៀបចំផែនការស្រាវជ្រាវទាក់ទង ទៅនឹងបច្ចេកទេសប្រមូលផលទឹកជ័រ នឹងរៀបចំទិន្នន័យសម្រាប់ចំណែកថ្នាក់ក្រុមក្លូនកៅស៊ូជាមួយជំនាញការ CIRAD



ការចុះទស្សនកិច្ចរបស់ក្រុមការងារសិក្សាលទ្ធភាពអាចធ្វើបាននៃគម្រោង RAD4CAM នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកម្ពុជា

# សកម្មភាពការងាររបស់ការិយាល័យសរីរវិទ្យា និងអាជីវកម្ម



សកម្មភាពវិភាគសរីរសាស្ត្រទឹកជ័រ
(Latex diagnosis-LD, Sucrose, Pi, R-SH)



ការវិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ
ដើម្បីផ្ទៀងផ្ទាត់សារធាតុគីមី





សកម្មភាពយកសំណាកទឹកជ័រដើម្បីវិភាគសរីរទឹកជ័រ





ការបណ្តុះបណ្តាលកសិករអំពីការបើកមុខចៀរ និងការចៀរជ័រ នៅខេត្តមណ្ឌលគិរី

# សកម្មភាពការងាររបស់ការិយាល័យសរីរវិទ្យា និងអាជីវកម្ម



ការវាស់ទំហំដើមកៅស៊ូតាមដានការលូតលាស់



ការចុះពិនិត្យជំងឺកៅស៊ូ នៅខេត្តកោះកុង





ការចុះទស្សនកិច្ចចម្ការពិសោធន៍ និងរោងចក្រកែច្នៃកៅស៊ូ របស់ក្រុមប្រឹក្សាភិបាល





ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារក្នុងក្របខណ្ឌគម្រោងរបស់អង្គការ WWF

## ៣.២. មន្ទីរពិសោធន៍ជាតិយថាប្រភេទ

មន្ទីរពិសោធន៍ជាតិយថាប្រភេទគឺជាផ្នែកដ៏សំខាន់មួយរបស់ *វ.ស.ក.ក* និងជាមន្ទីរពិសោធន៍ជាតិដែលមានតួនាទីនៅក្នុងការពង្រឹងគុណភាពផលិតកម្មកៅស៊ូធម្មជាតិកម្ពុជា។ សកម្មភាពការងាររបស់មន្ទីរពិសោធន៍ ក្នុងឆ្នាំ២០២១ រួមមាន៖

- បានរៀបចំឯកសារស្តង់ដារ ISO/IEC 17025: 2017
- អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017
- បានធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន២១៦សំណាក របស់និស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដែលបានមកសរសេរសារណាបទ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- បានធ្វើតេស្តកៅស៊ូសន្លឹក (RSS) របស់ វ.ស.ក.ក.សរុបចំនួន ៧២សំណាក ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដា CSR
- បានចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍អន្តរជាតិក្នុងក្របខ័ណ្ឌសមាគមកៅស៊ូអន្តរជាតិ (IRA) ចំនួន២លើក (ទី១២៤និងទី១២៥)
- បានធ្វើតេស្តប្រៀបធៀបក្នុងស្រុកជាមួយមន្ទីរពិសោធន៍មូលដ្ឋាន ចំនួន៨មន្ទីរពិសោធន៍ សម្រាប់លើកទី៦២ មានចំនួន ៤២សំណាក
- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ Zoom Cloud Meeting *"បទបង្ហាញស្តីពី ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណភាពនៃមន្ទីរពិសោធន៍ អនុលោមតាមស្តង់ដារ ISO/IEC 17025: 2017"* របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានវិភាគគុណភាពជ័ររបស់និស្សិតមកពី វិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ ដើម្បីសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- បានចុះបញ្ជិកាទទួលស្គាល់ និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ចំនួន៤ រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ចំនួន៣មន្ទីរពិសោធន៍
- បានរៀបចំលិខិតជូនដំណឹងទៅដល់បណ្តាក្រុមហ៊ុន ស្តីពីការចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រដោយផ្ទាល់ ២ដង/ឆ្នាំ សម្រាប់ឆ្នាំ២០២១
- បានរៀបចំលិខិតជូនដំណឹងទៅដល់បណ្តាមន្ទីរពិសោធន៍មូលដ្ឋាន ស្តីពីសំណើសុំចូលរួមធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក(Parallel tests) ៤ដង/ឆ្នាំ សម្រាប់ឆ្នាំ ២០២១





ការចុះទស្សនកិច្ចរបស់ក្រុមការងារនៃគម្រោង RAD4CAM នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

# សកម្មភាពការងារនៃមន្ទីពិសោធន៍ជាតិយថាប្រភេទ



សកម្មភាពនៃការធ្វើតេស្ត$P_0$ និងPRI



សកម្មភាពធ្វើការធ្វើតេស្តវីស្គូស៊ីធីមូនី



សកម្មភាពនៃការធ្វើតេស្តរកបរិមាណផេះ



សកម្មភាពនៃការធ្វើតេស្តរកបរិមាណអាសូត



សកម្មភាពនៃការកិនគំរូសំណាកឱ្យស្មើសាច់



សកម្មភាពនៃការធ្វើតេស្តរកអសុទ្ធភាព

# សកម្មភាពការងារនៃមន្ទីរពិសោធន៍ជាតិយថាប្រភេទ




សកម្មភាពការធ្វើតេស្តរកភាគរយសារធាតុហើរ

សកម្មភាពនៃការបញ្ចូលលទ្ធផលតេស្ត




បំពេញសំណុំឯកសារចុះបញ្ជិការោងចក្រ

ការពិនិត្យខ្សែសង្វាក់កិនជ័រកៅស៊ូ




សកម្មភាពពិនិត្យខ្សែសង្វាក់គ្រាប់ជ័រឆៅ

លោក **ហាក់ ម៉ុនឆួន** នាយករងវិទ្យាស្ថាន និង មន្ត្រីជំនាញមន្ទីរពិសោធន៍ជាតិយថាប្រភេទ បានដឹកនាំនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជំនាញវិទ្យាសាស្ត្រកៅស៊ូចុះសិក្សាស្រាវជ្រាវលើប្រធានបទស្តីពីលក្ខណៈរូបនៃកៅស៊ូសន្លឹកកែច្នៃចេញពីទឹកជ័រនៃក្លូន GT1, PB217 RRIM600 ដែលត្រូវបង្កកដោយអាស៊ីតស៊ុលផួរិចអាលុយមីញ៉ូមប៉ូតាស្យូមស៊ុលផាតដូរដេកាអ៊ីដ្រាតេ អាស៊ីតហ្វ័រមិច សាជូរខៀវ និងសាជូរស។ ការស្រាវជ្រាវនេះគឺមានគោលបំណងស្វែងយល់ពីឥទ្ធិពលនៃអាស៊ីតទាំង៤នេះលើរចនាសម្ព័ន្ធកៅស៊ូ និងគុណភាពផលិតផលសម្រេច។









សកម្មភាពនៃការបង្ហាញពីប៉ារ៉ាម៉ែត្រតេស្តជូនដល់ប្រតិភូ AFD បានមកទស្សនកិច្ចនៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ





## ៣.៣. ស្ថានីយអនុវត្ត

សកម្មភាពការងារ និងលទ្ធផលការងារនៅស្ថានីយអនុវត្តដែលបានអនុវត្តរួមមាន៖

- ត្រួតពិនិត្យការចាត់ចែងកម្លាំងចៀរជ័រ
- រៀបចំបែងចែកវានចៀរជ័រសម្រាប់កម្មករ
- ថែទាំកៅស៊ូកំពុងផ្តល់ផល
- វាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី
- អនុវត្តការងារបំពាក់សម្ភារលើដើមកៅស៊ូ (ចាន ស្លាបព្រា លួសចំណង លួសកងចាន) សម្រាប់ការចៀរជ័រឆ្នាំ២០២១
- ត្រួតពិនិត្យការងារកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ
- ត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនជ័រ គ្រឿងចក្របម្រើឲ្យការងារកសិកម្ម ម៉ាស៊ីនទឹកស្រោចស្រពកូនកៅស៊ូ ម៉ាស៊ីនភ្លើងបម្រុង ការថែទាំបណ្តាញទឹក បណ្តាញភ្លើង អគារស្នាក់នៅរបស់មន្ត្រីរាជការ បុគ្គលិកកម្មករ និងអគារកន្លែងធ្វើការ ត្រួតពិនិត្យការបង្កើតមុខចៀរលើដើមកៅស៊ូដែលបើកមុខចៀរថ្មី
- ផ្គត់ផ្គង់ប្រេងឥន្ធនៈដល់ផ្នែកគ្រឿងចក្រដឹកជញ្ជូន អង្ករ ទឹក ភ្លើងជូនមន្ត្រីរាជការ បុគ្គលិក កម្មករ និង សម្ភារប្រមូលផលជ័រ ជីគីមី ធាតុគីមីមួយចំនួនដល់ផ្នែកកសិកម្មនិងផ្នែកកែច្នៃកៅស៊ូសន្លឹក
- ត្រួតពិនិត្យការងារជួសជុលផ្លូវនៅក្នុងស្ថានីយ៍
- ត្រួតពិនិត្យការជួសជុលផ្ទះស្នាក់នៅរបស់កម្មករ បណ្តាញទឹកនិងបណ្តាញភ្លើង សាលារៀន សាលាសន្សំកុសល នៅក្នុងភូមិ៣២





## ៣.៤. ការបណ្តុះបណ្តាល និងផ្ទេរបច្ចេកវិទ្យា

ក្នុងការរួមចំណែកដល់ការអភិវឌ្ឍដំណាំកៅស៊ូ ទន្ទឹមគ្នានឹងការអភិវឌ្ឍផ្នែកធនធានមនុស្ស **វ.ស.ក.ក** បានយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាល ផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងផ្សេងៗទៅដល់ប្រតិបត្តិករកៅស៊ូ សំដៅផ្តល់នូវចំណេះដឹង ចំណេះធ្វើ ហើយនិងបង្កើននូវភាពជឿជាក់និងឱកាសជោគជ័យ នៅក្នុងការវិនិយោគលើផលិតកម្មដំណាំកៅស៊ូ។ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ត្រូវបានអនុវត្តលើគ្រប់មុខជំនាញទៅតាមវិធីសាស្ត្រផ្សេងៗដែលអាចធ្វើទៅបានមានដូចជា៖

- ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សាដូចជា៖ ការបណ្តុះបណ្តាលនិស្សិតសាលាជាតិកសិកម្មកំពង់ចាម ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រ ដំណាំកៅស៊ូ លើមុខវិជ្ជា៖ ១. ការវិភាគសរីរទឹកជ័រ ២. ការបង្កាត់ពូជ
- ការទទួលកសិករ និងសិស្ស និស្សិតធ្វើទស្សនកិច្ចសិក្សា និងកម្មសិក្សា
- ការទទួលនិស្សិតធ្វើសារណាបទ និងដឹកនាំសារណាបទមួយចំនួនដូចជា៖ ទទួលនិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន០៣នាក់ និងសាលាជាតិកសិកម្មកំពង់ចាមចំនួន០២នាក់ ដើម្បីសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។
- ទទួលគណៈប្រតិភូនៃទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ និងលោកបណ្ឌិត Eric Gohet ជំនាញការ CIRAD មកធ្វើទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ ចម្ការពិសោធន៍ និងរោងចក្រកែច្នៃកៅស៊ូសន្លឹកនៅស្ថានីយពិសោធន៍
- ទទួលក្រុមការងារសិក្សាលទ្ធភាពអាចធ្វើបាននៃគម្រោង RAD4CAM មកធ្វើទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ ចម្ការពិសោធន៍ និងរោងចក្រកែច្នៃកៅស៊ូសន្លឹកនៅស្ថានីយពិសោធន៍

## ៣.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា **វ.ស.ក.ក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការអន្តរជាតិជាច្រើនរួមមាន៖

❖ ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា។ នៅឆ្នាំ២០១៦ ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្តីអំពី « ***និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព*** » ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមាន គណៈប្រតិភូពីបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុបចំនួន៣៣០នាក់។ នៅឆ្នាំ២០១៧ **វ.ស.ក.ក** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ ដោយមានភ្ញៀវពី បណ្តាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺ៖ *កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី* អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

នៅឆ្នាំ២០២១នេះ វ.ស.ក.ក បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញប្រចាំឆ្នាំចំនួន២លើកជាមួយក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) ៖

១.The Virtual IRRDB Annual Meeting (30 March 2021)

២.IRRDB WEBINAR ON *Pestalotiopsis* LEAF DISEASE ( 4th August 2021)

❖ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ **វ.ស.ក.ក** បានធ្វើសហប្រតិបត្តិការជាមួយ *មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍន៍ (CIRAD)* នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នារយៈពេល៥ឆ្នាំ(២០២១-២០២៥) កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។ នៅឆ្នាំ២០២១នេះ **វ.ស.ក.ក** បានធ្វើការសហប្រតិបត្តិការលើការងារស្រាវជ្រាវផ្នែក គ្សេត្រសាស្ត្រ បង្កាត់ពូជ ការប្រមូលផលជ័រនិងសរីរសាស្ត្រទឹកជ័រ ជាមួយជំនាញការនៃមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិដើម្បីអភិវឌ្ឍកសិកម្ម (CIRAD)។ មិនតែប៉ុណ្ណោះ CIRAD បានចាត់តាំងជំនាញការម្នាក់មកប្រចាំការ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ហើយក៏បានធ្វើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងរួមគ្នាក្រោមគម្រោង *"ការព្យាករណ៍ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពអាចរកបាននៃកម្លាំងពលកម្ម លើខ្សែច្រវ៉ាក់ផលិតកម្មកៅស៊ូធម្មជាតិនៅអាស៊ីអាគ្នេយ៍"*។

❖ កិច្ចសហប្រតិបត្តិការជាមួយ CATAS

កិច្ចសហប្រតិបត្តិការរវាង **វ.ស.ក.ក** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើង ដោយបានចុះអនុស្សរណៈនៃការយោគយល់នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុង កូឡុមបូ ប្រទេស ស្រីលង្កា។ ក្នុងទិសដៅបង្កើននូវទំនាក់ទំនង និងសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ។ បន្ទាប់មក **វ.ស.ក.ក** និង CATAS បានចុះអនុស្សរណៈនៃការយោគយល់បំពេញបន្ថែមចំនួនបួនលើកគឺនៅឆ្នាំ២០១៨មួយលើក ឆ្នាំ២០១៩មួយលើក ឆ្នាំ២០២០មួយលើក និងឆ្នាំ២០២១មួយលើក ដើម្បីបន្តសុពលភាពនៃកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវរួមគ្នា។ នៅឆ្នាំ២០២១នេះ ក្រុមការងារ CATAS បានផ្តល់នូវរ៉ូឡូកិនជ័រ (RSS Sheeting Battery)ចំនួនពីរ និងធុងបង្កកជ័រចំនួន១២ ដល់ **វ.ស.ក.ក** ដើម្បីបម្រើការងារក្នុងរោងចក្រកែច្នៃកៅស៊ូសន្លឹក។

❖ កិច្ចសហប្រតិបត្តិការជាមួយ WWF

ការសហប្រតិបត្តិការរវាង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាមួយអង្គការ WWF។ នៅឆ្នាំ២០២១ នេះ **វ.ស.ក.ក** បានសហការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី (ចំនួន១០ចម្ការ) និងសហការក្នុងសកម្មភាពផលិតវីដេអូខ្លីៗស្តីពី "ការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ" ។

## ៣.៦. ការអនុវត្តថវិកាកម្មវិធី

ក្នុងឆ្នាំ២០២១ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានខិតខំយកចិត្តទុកដាក់បំពេញការងារតាមកម្មវិធីទី១ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ចនៃអនុកម្មវិធីទី១.៦ លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ។ នៅក្នុងអនុកម្មវិធីទី១.៦ នេះមានគោលបំណង " *កសាងបណ្តាញទិន្នន័យសម្រាប់ការផ្ទេរនូវបច្ចេកវិទ្យាដល់អ្នកដាំកៅស៊ូ ដើម្បីបង្កើន គុណភាពចម្ការនិងផលិតភាពដំណាំកៅស៊ូ សំដៅធ្វើឲ្យ*

*មាននិរន្តរភាពនិងវឌ្ឍនភាពសេដ្ឋកិច្ចដល់អ្នកដាំកៅស៊ូ ហើយនិងនិរន្តរភាពបរិស្ថាន"* ដែលមានចង្កោមសកម្មភាពចំនួន០៣គឺ៖

១.៦.១៖ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ

១.៦.២៖ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ

១.៦.៣៖ទទួលធ្វើសេវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ

៣.៦.១.ចង្កោមសកម្មភាពទី១ ៖ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ។ ក្នុងគោលបំណងសំខាន់គឺ៖ កសាងនូវទិន្នន័យគោល និងសិក្សាពីកត្តាវិជ្ជមាននិងអវិជ្ជមានតាមការវិភាគលទ្ធផល សម្រាប់ជាអំណះអំណាងមូលដ្ឋានក្នុងការផ្សព្វផ្សាយផ្តល់ជាមគ្គុទ្ទេសនិងចង្អុលបង្ហាញដល់ប្រតិបត្តិករនៅក្នុងការអភិវឌ្ឍដំណាំកៅស៊ូ ដើម្បីបញ្ចៀសនូវហានិយភ័យ ព្រមទាំងការរក្សាបាននូវនិរន្តរភាពផលិតកម្ម និងកំណើនផលចំណូលដល់អ្នកដាំកៅស៊ូ ហើយនិងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ដើម្បី *វ.ស.ក.ក* សម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញ នឹងទទួលលទ្ធផលបានដូចខាងក្រោម៖

- ចម្ការពិសោធន៍ ដែលបានបង្កើត តាមដាន និងស្រង់ទិន្នន័យ បានចំនួន៦១ចម្ការ
- ក្លូនដែលអភិវឌ្ឍ អភិរក្ស និងគ្រប់គ្រង បាន៧៤ក្លូន
- សំណាកទឹកជ័រត្រូវវិភាគសរីរៈ បានចំនួន៥២០សំណាក

ជាលទ្ធផលចុងក្រោយនៃការអនុវត្តចង្កោមសកម្មភាពទី១គឺ៖ ក្លូនកៅស៊ូថ្មីសមស្របនឹងលក្ខខណ្ឌអាកាសធាតុកម្ពុជា។ ការវាយតម្លៃ និងដាក់បញ្ចូលក្នុងអនុសាសន៍និងផ្សព្វផ្សាយឲ្យដាំដុះ ហើយនិងរុក្ខសម្ភារកៅស៊ូត្រូវបានអភិវឌ្ឍវិធីប្រើប្រាស់ជីមានប្រសិទ្ធភាពធានាដល់ការលូតលាស់កូនកៅស៊ូ និងកំណើនទិន្នផលនិងការថែទាំកៅស៊ូត្រូវបានណែនាំ។

៣.៦.២. ចង្កោមសកម្មភាពទី២ ៖ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ។ ក្នុងគោលបំណងសំខាន់គឺ៖សំដៅធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលយថាប្រភេទកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ដើម្បីទទួលបាននូវតម្លៃសមស្រប បង្កើនចំណូលដល់អ្នកដាំដុះកៅស៊ូ និងជំរុញនូវកំណើនសេដ្ឋកិច្ចសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- តេស្តអន្តរមន្ទីរពិសោធន៍និងតេស្តប្រៀបធៀបមន្ទីរពិសោធន៍មូលដ្ឋានដែលនឹងត្រូវធ្វើ២ដងក្នុងមួយឆ្នាំ
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍និងគុណភាពកៅស៊ូជាអន្តរជាតិ ដែលនឹងត្រូវធ្វើ២ដងក្នុងមួយឆ្នាំ
- ការធ្វើតេស្តគុណភាពកៅស៊ូ (CSR) ដែលនឹងត្រូវធ្វើ៤ដងក្នុងមួយឆ្នាំ
- ការធ្វើតេស្តនិងបញ្ជាក់គុណភាពកៅស៊ូ (CSR) ដែលនឹងត្រូវធ្វើទៅ៤ដងក្នុងមួយឆ្នាំ

ជាលទ្ធផលចុងក្រោយនៃការអនុវត្តចង្កោមសកម្មភាពទី២គឺ៖ការប្រមូលផលកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពចម្ការកៅស៊ូហើយនិងបង្កើនបាននូវប្រសិទ្ធភាពពលកម្ម ហើយនិងវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូត្រូវទទួលស្គាល់ជាអន្តរជាតិ តាមរយៈ IRA ទទួលសិទ្ធចេញវិញ្ញាបនបត្រ បញ្ជាក់គុណភាពកៅស៊ូ។

៣.៦.៣. ចង្កោមសកម្មភាពទី៣ ៖ ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។ ក្នុងគោលបំណង កសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ទាំងបរិមាណនិងគុណភាព ដើម្បីជំរុញការងារពិសោធន៍និងស្រាវជ្រាវឲ្យទទួលបាននូវលទ្ធផលល្អ កសាងនូវទិន្នន័យគ្រឹះបានរឹងមាំ ព្រមជាមួយគ្នានោះក៏មានការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីផ្តល់នូវភាពកក់ក្តៅក្នុងការរស់នៅនិងបរិស្ថានបំពេញការងារដល់ មន្ត្រីនិងនិយោជិក ដែលជាចលករសំខាន់ចូលរួមនៅក្នុងការជំរុញដល់ការងារស្រាវជ្រាវនិងអភិវឌ្ឍប្រកបដោយជោគជ័យ និងចីរភាព។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការបណ្តុះបណ្តាលធនធានមនុស្សនិងផ្ទេរបច្ចេកវិទ្យា
- ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ
- ការផ្តល់សេវាបច្ចេកទេសគាំទ្រ
- ការងារគ្រប់គ្រងរដ្ឋបាល

ដើម្បីធានាដល់ភាពជោគជ័យ លើសកម្មភាពនៃការអនុវត្តគម្រោងដោយផ្ទៀងផ្ទាត់លទ្ធផលដែលសម្រេចបានជាមួយនឹងសូចនាករ ដែលបានកំណត់នៅក្នុងផែនការ ការពិនិត្យ តាមដាន និងវាយតម្លៃគឺនឹងត្រូវធ្វើឡើង។ ការវាយតម្លៃនៃការអនុវត្តនេះត្រូវបានធ្វើឡើងនៅពេលកំពុងអនុវត្តរហូតដល់ការបញ្ចប់នៃគម្រោង ដោយនាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរបាយការណ៍ប្រចាំខែ របាយការណ៍ត្រីមាស របាយការណ៍ឆមាស របាយការណ៍ប្រចាំឆ្នាំ និងការចុះវាយតម្លៃដោយផ្ទាល់រៀងរាល់ឆ្នាំ។ **វ.ស.ក.ក** ក៏មានការរៀបចំជាគណៈកម្មការវាយតម្លៃផ្ទៃក្នុងផ្ទាល់ខ្លួនផងដែរ សម្រាប់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធានាបាននូវភាពច្បាស់លាស់ ហើយនិងភាពជោគជ័យនៃការអនុវត្តគម្រោង។

## ៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

- សាងសង់អាគារទីស្នាក់ការវិទ្យាស្ថាននៅភ្នំពេញ
- ជួសជុលផ្ទះស្នាក់នៅចំនួន១០ខ្នង បណ្តាញទឹក និងបណ្តាញភ្លើងរបស់កម្មករក្នុងភូមិ៣២
- ជួសជុលសាលារៀន សាលាសន្សំកុសលនៅក្នុងភូមិ៣២
- ជួសជុលលាបថ្នាំអាគារការិយាល័យនិងអាគារស្នាក់នៅរបស់មន្ត្រីរាជការនៅក្នុងស្ថានីយ
- ជួសជុលផ្លូវក្នុងចម្ការកៅស៊ូពិសោធន៍របស់ វ.ស.ក.ក.
- រៀបចំសោភ័ណ្ឌភាពនៅមុខអគារការិយាល័យ និងនៅមុខមន្ទីរពិសោធន៍ជាតិយថាប្រភេទក្នុងស្ថានីយ៍ ។



ទីស្នាក់ការវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា


ផ្ទះស្នាក់នៅរបស់កម្មករក្នុងភូមិ ៣២

## ៥.ទិសដៅការងារឆ្នាំ២០២២ និងសន្និដ្ឋាន

### ៥.១. ទិសដៅការងារឆ្នាំ២០២២

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- យកចិត្តទុកដាក់ក្នុងការកសាងធនធានមនុស្ស បំពេញឲ្យធនធានមនុស្សដែលខ្វះខាត
- ពង្រឹងការអនុវត្តគម្រោងផែនការ និងសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២២ ឲ្យមានប្រសិទ្ធិភាព
- ខិតខំពង្រឹងភាពជាដៃគូស្រាវជ្រាវជាមួយបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ និងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍ដើម្បីបានការទទួលស្គាល់ពី វ.ស.ក.ក. ក្នុងការប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- បន្តការយកចិត្តទុកដាក់លើការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ
- ពង្រឹងការអនុវត្តលើការបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ(C S R )សម្រាប់ការនាំចេញកៅស៊ូកែច្នៃ និងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិ ព្រមទាំងភាគីជាតិដូចជាបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ ហើយនិងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍
- ចូលរួមសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា
- ចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សលើមុខវិជ្ជាបច្ចេកទេសដាំដុះ ការប្រមូលផលទឹកជ័រ សរីរសាស្ត្រទឹកជ័រ ជំងឺ និងកត្តាចង្រៃលើដំណាំកៅស៊ូ
- ស្នើសុំការទទួលស្គាល់ប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017 ។

### ៥.២. សេចក្ដីសន្និដ្ឋាន

ការងារអនុវត្តសម្រេចបាន១០០% ធៀបទៅនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការថវិកាតាមកម្មវិធី មិនតែប៉ុណ្ណោះ សកម្មភាពស្រាវជ្រាវជាច្រើនទៀត ត្រូវបានអនុវត្តក្រៅពីផែនការដែលបានកំណត់នៅក្នុងកម្មវិធី។ លទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងមន្ត្រីរាជការ និយោជិតទាំងអស់ ជាមួយថ្នាក់ដឹកនាំ ***វ.ស.ក.ក*** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវ ក្នុងបេសកកម្មរបស់ខ្លួននិងផែនការ ដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះ ក៏មានការយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័នជំនាញជាអណាព្យាបាលរួមមាន៖ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*** ក្នុងការជំរុញការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជា ស្របតាមគោលនយោបាយអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា។ សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានដោយមានការចូលរួមពីបណ្ដាដៃគូជាតិ រួមមានប្រតិបត្តិករកៅស៊ូទាំងអស់ដែលបានផ្ដល់ការទុកចិត្ត ចូលរួមនិងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួមសហការពីបណ្ដាដៃគូអន្តរជាតិពាក់ព័ន្ធ ដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS, WWF,...។

## ៥. កម្រងរូបភាព និងសកម្មភាពការងារ

នៅរសៀលថ្ងៃទី០៧ ខែមករា ឆ្នាំ ២០២១ នេះដែរ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីបានអញ្ជើញបចុះពិនិត្យ និងជួបសំណេះសំណាលការងារជាមួយមន្ត្រីរាជការនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានទីតាំងស្ថិតនៅភូមិ៣២ ឃុំជីរោទ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ តាមរយៈនៃការចុះជួបសំណេះសំណាលនេះ ឯកឧត្តមរដ្ឋមន្ត្រី បានសម្តែងការគាំទ្រដល់ការងារស្រាវជ្រាវកៅស៊ូ ដោយបានជំរុញឱ្យវិទ្យាស្ថាន ខិតខំផ្តោតលើការស្រាវជ្រាវពូជកៅស៊ូ ដែលអាចផ្តល់ផលិតភាពខ្ពស់ និងអាចទទួលផលក្នុងរយៈពេលឆាប់។ ក្រៅពីនេះ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានណែនាំវិទ្យាស្ថាន ចូលរួមសិក្សាស្វែងយល់ការសិក្សាផ្នែកដំណាំកៅស៊ូ ការចែករំលែកនូវបច្ចេកទេស និងបច្ចេកវិទ្យាទំនើបៗ ដល់សាកលវិទ្យាល័យក្នុងការទាក់ទាញសិស្សនិស្សិត។ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានណែនាំឱ្យវិទ្យាស្ថាន ខិតខំសហការជាមួយវិស័យឯកជនដែលវិនិយោគលើដំណាំកៅស៊ូ និងសហការជាមួយបណ្តាប្រទេសក្នុងតំបន់ ដើម្បីចែករំលែកនូវបទពិសោធន៍ និងលទ្ធផលនៃការស្រាវជ្រាវនូវបច្ចេកវិទ្យាថ្មីៗ។













នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២១ នេះដែរ ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃ វ.ស.ក.ក. អញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល **វ.ស.ក.ក.** លើកទី៩ អាណត្តិឆ្នាំ២០២០-២០២៣ លើរបៀបវារៈចំនួនពីរ៖ (១) ពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវកៅស៊ូក្នុងឆ្នាំ២០២១ របស់ **វ.ស.ក.ក** និង(២)បញ្ហាផ្សេងៗ នៅស្ថានីយ៍អនុវត្តនៃ វ.ស.ក.ក.នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។










ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលនៃ វ.ស.ក.ក អញ្ជើញទស្សនកិច្ច ចម្ការពិសោធន៍ មន្ទីរពិសោធន៍ជាតិយថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូសន្លឹក RSS នៅស្ថានីយ៍អនុវត្តនៃ វ.ស.ក.ក.នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។


















ការប្រជុំផ្ទៃក្នុងរបស់ថ្នាក់ដឹកនាំនៃ **វ.ស.ក.ក** ដើម្បីពិនិត្យនិងពិភាក្សាអំពីវឌ្ឍនភាពការងារឆ្នាំ ២០២១ និងលើកទិសដៅសម្រាប់អនុវត្តក្នុងឆ្នាំ២០២២






នៅថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០២១ **លោក លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចូលរួមប្រជុំក្រុមប្រឹក្សា នៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ តាមប្រព័ន្ធអនឡាញ




នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នាព្រឹកថ្ងៃពុធ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ លោក **លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **ម៉ាន សុទ្រី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រព័ន្ធវីដេអូហ្សូម(Zoom Meeting)។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងកសិកម្ម លោកអគ្គលេខាធិការរងក្រសួងកសិកម្ម លោកអគ្គនាយករង លោកប្រធាននិងលោក លោកស្រីអនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកៅស៊ូ ។




កិច្ចប្រជុំតាមZoom របស់ការិយាល័យ ផែនការ និងគណនេយ្យ សេចក្តីព្រាងគោលការណ៍ណែនាំស្តីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង




សកម្មភាពនៃការពិភាក្សាអំពីការគ្រប់គ្រងផ្ទាំងចៀរ នៅចម្ការពិសោធ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា




សកម្មភាពរៀបចំបណ្តាញទុយោទឹកថ្មី នឹងបណ្តាញអគ្គិសនី នៅក្នុងភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ




នៅថ្ងៃទី ១៩ ខែ១០ ឆ្នាំ២០២១ លោក **ឧកញ្ញា លីយ៉ុងផាត់** ចុះមកទស្សនកិច្ចរោងចក្រកែច្នៃកៅស៊ូសន្លឹក របស់ ***វ.ស.ក.ក***




សកម្មភាពរៀបចំផលិតវីឌីអូបច្ចេកទេសក្នុងការប្រមូលផលជ័រកៅស៊ូ






នាព្រឹកថ្ងៃព្រហស្បតិ៍ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ លោក **ហាក់ ប៊ុនធួន** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងជាប្រធានគណៈកម្មការបច្ចេកទេសទី៧ ផ្នែកផលិតផលកៅស៊ូ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិលើកទី២៤ តាមប្រព័ន្ធ Video Conference Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ។ ក្នុងកិច្ចប្រជុំនេះដែរមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាដែលបានអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបចំនួន ៧០រូប ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត ស្តង់ដារអន្តរជាតិ ISO IEC និង UNECE ពាក់ព័ន្ធនឹងផ្នែកសំណង់ សម្ភារសាងសង់ សារធាតុនិងផលិតផលគីមី ប្រព័ន្ធគ្រប់គ្រងផលិតផលអគ្គិសនីនិងអេឡិចត្រូនិច កៅស៊ូយានយន្ត គ្រឿងសម្អាង និងផ្នែកឱជីថល ធ្វើជាស្តង់ដារជាតិ។ ជាលទ្ធផល អង្គប្រជុំបានអនុម័តទទួលយកស្តង់ដារអន្តរជាតិ ចំនួន ២០ស្តង់ដារជាស្តង់ដារជាតិ។





នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ក្រុមការងារបច្ចេកទេសនៃក្រុមហ៊ុនចំការកៅស៊ូមេមត់ខូអិលធីឌី បានអញ្ជើញមកពិភាក្សាជាមួយមន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អំពីការជ្រើសរើសក្លូនកៅស៊ូសម្រាប់ធ្វើការដាំដុះ និងកិច្ចសហការលើការងារស្រាវជ្រាវកៅស៊ូ។









នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១ ប្រតិភូនៃទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ និងលោកបណ្ឌិត Eric Gohet ជំនាញការ CIRAD បានអញ្ជើញមកធ្វើទស្សនកិច្ច មន្ទីរពិសោធន៍ជាតិយថាប្រភេទ ចម្ការពិសោធន៍ និងរោងចក្រកែច្នៃកៅស៊ូសន្លឹកនៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ គោលបំណងនៃដំណើរទស្សនកិច្ចនេះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងសិក្សាលទ្ធភាពក្នុងការជួយដល់វិស័យស្រាវជ្រាវកៅស៊ូកម្ពុជា។


















នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ការចុះទស្សនកិច្ចរបស់ក្រុមការងារសិក្សាលទ្ធភាពអាចធ្វើបាននៃគម្រោង RAD4CAM នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា










ចាប់ពីថ្ងៃទី១៥ ដល់ ១៩ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងក្របខណ្ឌគម្រោងភាពជាដៃគូពហុភាគី (MAP) មន្ត្រីជំនាញនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សហការជាមួយក្រុមការងារអគ្គនាយកដ្ឋានកៅស៊ូ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី និងអង្គការ WWF បានចុះរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័រ ចម្ការកៅស៊ូគ្រួសារចំនួន៩ចម្ការ នៅក្នុងឃុំគោលដៅចំនួន៤រួមមាន ឃុំពូជ្រៃ(២ចម្ការ) ឃុំក្រង់តេះ(៣ចម្ការ) ឃុំស្រែអំពូម(១ចម្ការ) និង ឃុំប៊ូស្រា (៣ចម្ការ) ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ឆ្លៀតឱកាសនៃការរៀបចំចម្ការបង្ហាញនេះ ក្រុមការងារបានធ្វើការណែនាំបច្ចេកទេសដល់កសិករមានដូចជា៖ ១. ការធ្វើផ្លូវភ្លើង ២. ការសម្អាតព្រៃក្នុងចម្ការ ៣. ការលាបប៉េត្រូឡាតូមលើផ្ទាំងមុខចៀរ ៤. ការសម្អាតផ្ទាំងមុខចៀរនិងចានត្រងជ័រ និង៥. ការប្រឹក្សាបច្ចេកទេស ផ្សេងៗទៀតដល់កសិករ។













# ឯកសារបោះពុម្ពផ្សព្វផ្សាយ



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ឯកសារផ្សព្វផ្សាយ ២០២១.០៨

## វិធីដាំកូនកៅស៊ូធំត្រូ

ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងកសិករ

កូនកៅស៊ូដាំដោយកូន១ឆ្នាំប្លាស្ទិក

កូនកៅស៊ូមានអាយុ ៥ខែ ដាំដោយកូន ១ឆ្នាំប្លាស្ទិក

៧. លុបអាចម៍ដីនិងជាន់បង្ហាប់លើកទី៣ រហូតដល់អាចម៍ដីពេញរណ្ដៅជាការសម្រេច។ ក្រោយពេលដាំកូនកៅស៊ូរួច រាល់គេលោតស៊ំបកថង់គ្រប់គល់ ឬប្រមូលយកចេញពីចម្ការ។

៨. គេលុបដីទុកប្រវែងប្រមាណ ២ធ្នាប់ដៃ ខាងក្រោមថ្នាក់បំពៅ ប្រដាគក្បាំងឬស្មើចម្ងាយប្រមាណ ០៥-១០ស.មពីកូនកៅស៊ូ ដើម្បីការពារការប៉ះពាល់ដោយសត្វឬការផ្សេងៗ។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាសយដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

1/2

### វិធីដាំកូនកៅស៊ូធំត្រូ

១. រណ្ដៅដាំកូនកៅស៊ូមានទំហំ ០.៥០ម x ០.៥០ម x ០.៥០ម។ ពេលកាប់រណ្ដៅ ដីស្រទាប់លើដាក់ទៅម្ខាង ឯស្រទាប់ក្រោមដាក់ទៅម្ខាងទៀត។ នៅពេលលុបរណ្ដៅ យកដីស្រទាប់លើលុបជាមុន ទើបយកស្រទាប់ក្រោមលុបបំពេញរណ្ដៅ។

២. ដាក់ជី NPK 15-15-15 ប្រមាណ ១០០ក្រាម ជាមួយអាចម៍ដីជុំវិញមាត់រណ្ដៅ ច្របល់ឱ្យសព្វល្អ។

៣. កាត់បាតថង់ប្រមាណ ១ស.ម (ក្នុងករណីនេះត្រូវប្រុងប្រយ័ត្ន ចៀសវាងកុំអោយបាក់ខ្ទេចកូនកៅស៊ូដែលដុះ និងបែកដីក្នុងថង់)។

៤. លើកកូនកៅស៊ូដាក់ចូលទៅក្នុងរណ្ដៅ ដោយដាក់ថ្នាក់បំពៅដែលដុះខ្វែងចេញមកបែរទៅទិសខាងកើត ដើម្បីជួយការពារកុំឱ្យងាយបាក់បែកដោយសារខ្យល់ ហើយរះថង់តាមបណ្ដោយពីក្រោមមក លើត្រឹម ១,៣ថង់ ដោយប្រយ័ត្នកុំឱ្យបែកដី។

៥. ដៃទាំងពីរចាប់លាត់ថង់ឡើងលើត្រឹម ១,៣ នៃថង់ កាយអាចម៍ដីដែលលាយច្របល់ជាមួយជីលុបជុំវិញ ច្រកជាន់បង្ហាប់ដីកូនកៅស៊ូអោយរហាប់ណែនល្អ។ គេចាប់លាត់ថង់ លុបអាចម៍ដី និងជាន់បង្ហាប់លើកទី២ នៅប្រវែង ២,៣ ពីបាតថង់។

៦. ទាប់លាត់ថង់ដោយថ្នមៗចេញទាំងស្រុង។

2/2

# ឯកសារបោះពុម្ពផ្សព្វផ្សាយ

**ខ) ឆ្នាំទី២**

- ត្រូវជម្រះតាមជួរកៅស៊ូឱ្យបាន១ម៉ែត្រពីគល់កៅស៊ូ
- គ្រប់គ្រងចន្លោះជួរឱ្យបានល្អ (ត្រួសល្បាស់ព្រៃឱ្យខ្ទី ឬអាចធ្វើដំណាំចន្លោះជួរ)
- កាត់ខ្នែងកូនកៅស៊ូរហូតដល់កំពស់ ២.៥ម
- គ្របគល់កូនកៅស៊ូ (សំណល់រុក្ខជាតិមានដូចជា ដើមសណ្តែក ចំបើង...)
- ជួសកូនកៅស៊ូដែលងាប់ដោយប្រើកូនកៅស៊ូធំត្រចិល្អ ដើម្បីដុះលូតលាស់ទាន់គ្នា
- ដាក់ជីតាមតំរោង

ក្នុងការសម្អាតស្មៅតាមជួរកៅស៊ូ គេអាចប្រើថ្នាំសម្លាប់ស្មៅបាន ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។

**គ) ឆ្នាំទី៣**

- ត្រូវជម្រះតាមជួរកៅស៊ូឱ្យបាន១ម៉ែត្រពីគល់កៅស៊ូ
- គ្រប់គ្រងចន្លោះជួរឱ្យបានល្អ (ត្រួសល្បាស់ព្រៃឱ្យខ្ទី ឬអាចធ្វើដំណាំចន្លោះជួរ)
- កាត់ខ្នែងកូនកៅស៊ូរហូតដល់កំពស់ ២.៥ម
- ដាក់ជីតាមតំរោង
- បាញ់ថ្នាំការពារ-ព្យាបាលជំងឺផ្កាកុលាប បើសិន

**ឃ) ឆ្នាំទី៤**

- បាញ់ថ្នាំសម្លាប់ស្មៅតាមជួរកៅស៊ូចំនួន២ដង
- ដាក់ជីតាមតំរោង
- បាញ់ថ្នាំការពារ-ព្យាបាលជំងឺផ្កាកុលាប
- ត្រួសល្បាស់ព្រៃនៅចន្លោះជួរឱ្យបាន២-៣ដង ក្នុងមួយឆ្នាំទៅតាមល្បាស់តិច ឬច្រើន

**ង) ឆ្នាំទី៥ និងទី៦ ឬទី៧**

- ត្រូវថែទាំដូចគ្នានឹងឆ្នាំទី៤ដែរ។ នៅឆ្នាំទី៥ មានដើមកៅស៊ូ (កូន) ខ្លះអាចបើកមុខចៀរជ័របាន។ ឯឆ្នាំទី៦គឺជាឆ្នាំដែលស្ទើរតែគ្រប់ដើមកៅស៊ូទាំងអស់ត្រូវបានបើកមុខចៀរយកជ័រ បើសិនជាថែបានត្រឹមត្រូវតាមបច្ចេកទេស។

**សម្គាល់៖ ក្នុងការសម្អាតស្មៅ គេច្រើននិយមប្រើថ្នាំសម្លាប់ស្មៅក្នុងការថែទាំចម្ការកៅស៊ូមិនទាន់ផ្តល់ផល។ ទោះជាយ៉ាងណាក្តីក៏មិនត្រូវប្រើដោយប្រថុយដែរ គឺត្រូវធ្វើតាមបច្ចេកទេស។**

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

| | |
|---|---|
| ទូរស័ព្ទ/ទូរសារ | : (855) 78 682222 |
| សារអេឡិចត្រូនិច | : crri@camnet.com.kh |
| វិបសាយ | : www.crri.com.kh |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២១/០៦

## របៀបថែទាំកូនកៅស៊ូ

### ក្រោយពេលដាំរហូតបើកមុខចៀរ



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យផ្សព្វផ្សាយនិងការពារ



**របៀបថែទាំកូនកៅស៊ូ**

កូនកៅស៊ូចាប់ពីដាំរហូតដល់ឆ្នាំដែលគេសន្និដ្ឋានថា មានលក្ខណៈអាចចៀរជ័របានត្រូវបានសន្មតថា នៅក្នុងវ័យមិនទាន់ផ្តល់ផល ដែលមានអាយុពី៥ ដល់៧ឆ្នាំទៅតាមពូជ ប្រភេទកូន របៀបដាំ ជីជាតិដី និងបច្ចេកទេសថែទាំ។

ក្នុងវ័យមិនទាន់ផ្តល់ផលនេះ ត្រូវដាក់ជីឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ គុណភាព ថែទាំឱ្យបានជិតដល់ និងធ្វើឱ្យវាមានដើមធំសម្រាប់ស្រួលចៀរយកជ័របានពេញលេញនៅថ្ងៃក្រោយ។

នៅប្រទេសកម្ពុជាយើង ដែលមានភាពរាំងស្ងួតរយៈពេលច្រើនខែ ចាប់ពីឆ្នាំដាំទៅ ត្រូវធ្វើយ៉ាងណាកុំឱ្យស្មៅព្រៃប្រជែងជញ្ជក់ទឹក-ជីជាមួយនឹងកូនកៅស៊ូ និងកុំឱ្យទឹកនោះធ្លាប់ហូរចេញពីដី។ ពន្លឺក៏ត្រូវឱ្យចូលគ្រប់គ្រាន់សម្រាប់ឱ្យកូនកៅស៊ូលូតលាស់បានល្អដែរ។

ទន្ទឹមនេះ កូនកៅស៊ូក្នុងវ័យនេះត្រូវការធាតុចិញ្ចឹមជាចាំបាច់សម្រាប់ការលូតលាស់ ជាពិសេសធាតុអាសូត(N) ហ្វូស្វ័រ (P) និងប៉ូតាស្យូម(K)។ ស្មៅព្រៃអាចដណ្តើមជញ្ជក់ធាតុចិញ្ចឹមពីកូនកៅស៊ូដែលជាហេតុនាំឱ្យកូនកៅស៊ូនៅក្រិន។

ក្នុងឆ្នាំទី១ដល់ឆ្នាំទី៦ក្រោយពេលដាំ ត្រូវមើលថែទាំកូនកៅស៊ូដូចតទៅ៖

**ក) ឆ្នាំទី១**

**១. ការសម្អាតស្មៅ**

បន្ទាប់ពីដាំកូនកៅស៊ូរួច ត្រូវជម្រះស្មៅតាមជួរកូនកៅស៊ូឱ្យបាន១ម៉ែត្រយ៉ាងតិចពីគល់កូនកៅស៊ូ។ ក្នុងការជម្រះស្មៅតាមជួរកូនកៅស៊ូនេះគេច្រើនជម្រះ ២៥-៣០ថ្ងៃម្តងនៅក្នុងរដូវភ្លៀង។ នៅក្នុងឆ្នាំដំបូង គេអាចជម្រះស្មៅដោយប្រើកម្លាំងកម្មករឱ្យជម្រះនឹងចប តែមិនប្រើថ្នាំសម្លាប់ស្មៅទេ ព្រោះកូនកៅស៊ូនៅក្មេងខ្ចី លើកលែងតែគេអាចគ្រប់គ្រងបានម៉ត់ចត់។



**២. គ្របគល់**

នៅចុងរដូវភ្លៀង ខែតុលាឬដើមខែវិច្ឆិកា គេអាចយកសំណល់រុក្ខជាតិ ដូចជា ចំបើង ស្លឹកឈើ ដើមសណ្តែក ឬដើមអំបូរលេគុយមីណឹដែលដាំតាមចន្លោះជួរមកគ្របជុំវិញគល់ដើម្បីការពារកុំឱ្យទឹកហួតឆាប់ ហើយដើមរុក្ខជាតិដែលគេយកមកគ្របគល់នេះអាចរលួយទៅជាជីធម្មជាតិ។

**៣. ជួសកូនដែលងាប់**

បើមានកូនកៅស៊ូណាងាប់ ត្រូវដាំជួសឱ្យអស់ និងទាន់ក្នុងឆ្នាំទី១នេះទើបល្អប្រសើរ។

**៤. កាត់ខ្នែង**

ការងារនេះត្រូវចាប់ផ្តើមធ្វើភ្លាមពីក្រោយពេលដាំ ដើម្បីកុំឱ្យកូនកៅស៊ូឆាប់បែកមែក ដោយដើរត្រួតពិនិត្យមើល១៥ថ្ងៃម្តង។

**៥. ដាក់ជីក្រោយពេលដាំ**

ជីត្រូវដាក់ទៅតាមតំរោងដែលបានកំណត់ តាមធម្មតាក្រោយពេលដាំរួចត្រូវដាក់នៅចុងរដូវភ្លៀងម្តងទៀត។ ក្នុងមួយឆ្នាំត្រូវដាក់ជី២ដងគឺដើមរដូវភ្លៀងម្តង(ខែឧសភា)និងចុងរដូវភ្លៀងម្តងទៀត(ខែតុលា)។

**៦. ការគ្រប់គ្រងចន្លោះជួរ**

នៅចន្លោះជួរ កសិករអាចដាំដំណាំប្រចាំឆ្នាំដូចជា៖ សណ្តែក...ដែលជួយធ្វើឱ្យដីមានជីជាតិពិសេសអាសូត។ ក្នុងករណីពុំមានដំណាំចន្លោះជួរទេត្រូវត្រួសល្បាស់ព្រៃឱ្យខ្ទី។



**៧. ការពារភ្លើងឆេះ**

ត្រូវធ្វើផ្លូវភ្លើងព័ទ្ធជុំវិញចម្ការ ដើម្បីការពារភ្លើងឆេះកូនកៅស៊ូនៅរដូវប្រាំង។

# ឯកសារបោះពុម្ពផ្សព្វផ្សាយ

### ១. សេចក្ដីផ្ដើម

ការប្រើប្រាស់ជីគឺជាកត្តាសំខាន់ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការលូតលាស់និងទិន្នផលកៅស៊ូ ទន្ទឹមនឹងនោះការវិនិយោគទុនដើម្បីដាំដំណាំកៅស៊ូក៏មានអត្រាការខ្ពស់ដែរ ដូច្នេះការកំណត់បរិមាណនៃការប្រើប្រាស់ជីមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការសន្សំសំចៃទុននៅក្នុងរយៈពេលដើមកៅស៊ូមិនទាន់ផ្ដល់ផលនិងកៅស៊ូផ្ដល់ផល។ ការជំរុញនិងលូតលាស់របស់ដើមកៅស៊ូមានតម្រូវការជីជាតិគ្រប់មុខទាំងអស់រួមមាន N, P, K, Mg, Ca, S, Fe, Cu, Zn, Mo, Bo, …តម្រូវការជីជាតិនេះមានលក្ខណៈខុសៗគ្នាទៅនឹងរុក្ខជាតិផ្សេងៗទៀត ប៉ុន្តែសម្រាប់ដំណាំកៅស៊ូត្រូវការ N, P, K និង Mg ហើយសារធាតុផ្សេងៗទៀតសឹងតែមានគ្រប់គ្រាន់នៅក្នុងដី។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថាដំណាំកៅស៊ូត្រូវការជីច្រើនដើម្បីលូតលាស់បានល្អក្នុងរយៈពេលមិនទាន់ផ្ដល់ផល ប៉ុន្តែក៏មិនមានឥទ្ធិពលលើការលូតលាស់ដើម ចំពោះកៅស៊ូផ្ដល់ផលទេ។ ទោះបីយ៉ាងណាក៏ដោយ គឺត្រូវពិនិត្យទៅលើការប្រើប្រាស់ជីដោយសន្សំសំចៃ ដើម្បីទទួលផលចំណេញ។




### ២. វិធីសាស្ត្រគណនាបរិមាណជីត្រូវប្រើ

១. ការគិតពិចារណាលើស្ថានភាពជីវជាតិ Nutrient ត្រូវផ្អែកលើសារធាតុសំខាន់ៗដូចជា N, P, K និង Mg ដែលមាននៅក្នុងដីនិងស្លឹក។ ការគិតពិចារណាបន្ថែមទៀតទៅលើស្ថានភាពជីវជាតិត្រូវផ្អែកលើប្រភេទដីអាស៊ីតឬដីបាសដែលមាននៅក្នុងមេភាគ។

២. មូលដ្ឋានគ្រឹះនិងលក្ខណៈវិទ្យាសាស្ត្រនៃការបង្កើតអនុសាសន៍ប្រើប្រាស់ជីត្រូវផ្អែកលើកត្តាដូចខាងក្រោម៖

ក- ការវិភាគដីនិងស្លឹករួមមាន ការវិភាគសារធាតុសរុបទាំងអស់ដូចជា N, P, K និង Mg ដែលមានក្នុងស្លឹកនិងវិភាគ pH, C, N, P, K, Mg ប៉ុន្តែប៉ូល P បន្ទាស់ ឬ K និង Mg ដែលមានក្នុងដី។

ខ- ទិន្នផលកៅស៊ូយោងទៅតាមសមត្ថភាពផលិតនៃកូន ប្រព័ន្ធចៀរជ័រនិងការប្រើប្រាស់ថ្នាំញោច

គ- ការលូតលាស់និងគុណភាពចម្ការកៅស៊ូរួមមានកំណើននៃការលូតលាស់ទំហំដើមកៅស៊ូផ្ដល់ផល ចំនួនដើមចៀរដែលមានគុណភាពខ្ពស់ ចង្វាក់ចៀរជ័រក្នុងមួយឆ្នាំ បច្ចេកទេសនៃការចៀរជ័រ ស្ថានភាពមុខចៀរ ស្ថានភាពការណ្ដាតី (Canopy) ស្លឹកកៅស៊ូ ផលប៉ះពាល់នៃជំងឺទៅលើទិន្នផល

ឃ- ទម្រង់នៃការដាក់ជីលើចម្ការកៅស៊ូមានដូចជាប្រភេទ កម្រិតនៃការប្រើប្រាស់ជី ចំនួននៃការដាក់ជីក្នុងមួយឆ្នាំ និងបច្ចេកទេសនៃការដាក់ជី…

ង- បទពិសោធន៍និងជំនាញនៃការប្រើប្រាស់ជីរួមផ្សំជាមួយនិងកត្តាដែលមានឥទ្ធិពលលើទិន្នផលនិងការកែសម្រួលកម្រិតនិងចំនួនការប្រើប្រាស់ជីនិងកត្តាឥទ្ធិពលផ្សេងៗទៀត។



1/2

### ៣. ផ្ទាំងមុខចៀរឆ្លើយតបទៅនឹងការប្រើប្រាស់ជី




(រាងពងក្រពើពណ៌ទឹកក្រូច) មេតាបូលីសអតិបរិមា ការផ្ដល់ជាតិស្ករខ្ពស់ ការប្រើប្រាស់ជីមានប្រសិទ្ធភាពខ្ពស់ (LD ++, +, = +)

(រាងពងក្រពើពណ៌ខៀវ) ការផ្ដល់ជាតិស្ករមានកម្រិត ការប្រើប្រាស់ជីបានផ្ដល់ផលមធ្យម (LD =, = –)

✖ មេតាបូលីសមានកម្រិតទាប ការប្រើប្រាស់ជីមិនសូវមានប្រសិទ្ធភាព (LD =, = –)

▲ មេតាបូលីសមានកម្រិតទាបបំផុត ការប្រើប្រាស់ជីមិនមានប្រសិទ្ធភាព (LD –, – –)

សំគាល់: DL= Latex Diagnosis

### ៤. តារាងការប្រើប្រាស់ជីលើកៅស៊ូផ្ដល់ផល

| (ឆ្នាំ) | [illegible] | [illegible] | [illegible] | [illegible] |
|---|---|---|---|---|
| 1 | - | 47 | - | - |
| 2 | 87 | 68 | 54 | 18 |
| 3 | 112 | 72 | 72 | 24 |
| 4 | 138 | 90 | 72 | 24 |
| 5 | 120 | 108 | 96 | 36 |
| 6 | 101 | 90 | 120 | 36 |

### ៥. អនុសាសន៍នៃការប្រើប្រាស់ជីលើកៅស៊ូផ្ដល់ផល

- តម្រូវការជីនៃតំបន់មួយគឺពឹងផ្អែកលើលទ្ធផលវិភាគ ដី ស្លឹក អាយុដើមកៅស៊ូ កូន ការលូតលាស់ជង់ស៊ីតេការណ្ដាតី និងលក្ខណៈសំខាន់ដទៃទៀតរួមមាន ប្រវត្តិនៃដំណាំកៅស៊ូ ការដាក់ជីពីអតីតកាល ទម្រង់និងភាពមានភាពជី ដើម្បីវាយតម្លៃពីបរិមាណនិងចំនួនដងនៃការប្រើប្រាស់ជី
- ការប្រើជីលើកៅស៊ូផ្ដល់ផលមិនមានឥទ្ធិពលលើការលូតលាស់ដើមកៅស៊ូទេ
- ការប្រើជីលើកៅស៊ូផ្ដល់ផលដែលមានលក្ខណៈសេដ្ឋកិច្ចគឺពេលផ្ទាំងមុខចៀរមានមេតាបូលីសអតិបរិមា ការផ្ដល់ជាតិស្ករខ្ពស់
- ការប្រើជីលើកៅស៊ូផ្ដល់ផលដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ត្រូវអនុវត្តលើផ្ទាំងមុខចៀរឆ្លើយតបទៅនឹងការប្រើប្រាស់ជី។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាសយដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (855) 78 682222
សារអេឡិចត្រូនិច : crri@camnet.com.kh
វេបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២១/០៨

## ការប្រើប្រាស់ជីលើកៅស៊ូផ្ដល់ផល
## Fertilizer application on mature rubber



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យផ្សព្វផ្សាយនិងការងារ

2/2

# ឯកសារបោះពុម្ពផ្សព្វផ្សាយ

## ២. កំហាប់នៃថ្នាំរំញោច

ចំពោះកំហាប់ 2,5% នៃល្បាយថ្នាំរំញោចដែលត្រូវលាប បរិមាណកំណត់ជាមធ្យម គឺ១ក្រាមសម្រាប់លាបមួយដើម សម្រាប់ការចៀរពាក់កណ្ដាលតួទម្រង់ (S/2)។ ករណីចៀរឡើងលើ (S/4U) ឬចៀរសម្រាប់ដើមចុងក្រោយ ល្បាយថ្នាំរំញោចអាចមានកំហាប់អេតេហ្វុន 5%។

ដើម្បីចៀសវាងការរំញោចលើសកម្រិត បរិមាណដែលបានកំណត់នៃរូបធាតុសកម្ម (ជាមិលីក្រាមសម្រាប់មួយដើមក្នុងមួយឆ្នាំ) មិនត្រូវឱ្យលើសជាដាច់ខាត។ បរិមាណនេះ គឺអាស្រ័យទៅតាមក្រុមក្លូនកៅស៊ូនិងប្រព័ន្ធចៀរ។

## ៣. ចំនួនជុំ (Rounds) នៃការរំញោច

ការរំញោចមួយលើក ទៅមួយលើកទៀត ត្រូវមានគម្លាតពេលគ្រប់គ្រាន់ ដើម្បីទុកឱ្យដើមកៅស៊ូមានពេលអាចបង្កើតទឹកជ័រឡើងវិញ ស្របទៅតាមបរិមាណថ្នាំនិងប្រព័ន្ធចៀរដែលគេប្រើ។ ការរំញោចនេះត្រូវធ្វើច្រើនដង ឬ តិចក្នុងមួយឆ្នាំ គឺអាស្រ័យទៅតាមក្រុមក្លូន (Clonal typology)។

## ៤. ពេលត្រូវរំញោច

- ការរំញោចត្រូវប្រព្រឹត្តទៅឱ្យបានមុនការចៀរជ័រ ពី២៤-៤៨ម៉ោង អាស្រ័យតាមចង្វាក់ចៀរ។

ការរំញោចលើសកំណត់ អាចធ្វើឱ្យមានវិបត្តិដល់សរីរៈនៃដើមកៅស៊ូនិងបណ្ដាលឱ្យដើមកៅស៊ូអន់ខ្សោយ ដែលអាចនាំឱ្យសម្បកស្ងួត ទឹកជ័រលែងហូរ និងនាំឱ្យមានបាតុភូតដែលគេហៅថា **ស្ងួតមុខចៀរ** (Tapping Panel Dryness)។

## ការប្រុងប្រយ័ត្ន

ក្នុងការរំញោច ត្រូវប្រុងប្រយ័ត្នដូចតទៅ ៖

- ត្រូវចៀសវាងធ្វើការរំញោចក្នុងពេលដែលដើមកៅស៊ូកំពុងជ្រុះនិងដុះស្លឹកឡើងវិញ
- មិនត្រូវលាបថ្នាំរំញោចនៅពេលភ្លៀង
- ត្រូវរក្សាទុក ឬដឹកជញ្ជូនល្បាយសារធាតុរំញោចនៅក្នុងធុងមិនមែនលោហៈ។

សូមទាក់ទងជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បើលោក-អ្នកចង់ដឹងលម្អិតអំពីការរំញោច។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានលេខ 59E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបច្ចេកទេស ២០២១/១០

# ការរំញោចទឹកជ័រដោយប្រើអេតេហ្វុន



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យសរីរវិទ្យានិងអាជីវកម្ម

1/2

## និយមន័យការរំញោច (Stimulation)

ការរំញោច គឺជាវិធីប្រើផលិតផលគីមីដើម្បីទាញយកទឹកជ័រឱ្យបានច្រើន ដោយពុំមិនធ្វើឱ្យមុខសរសៃជ័រទាប់ស្ទះ និងធ្វើឱ្យទឹកជ័រហូរចេញបានយូរជាលទ្ធផល ការរំញោចធ្វើឱ្យកសិករទទួលបានជ័រកៅស៊ូច្រើន ដោយពុំចាំបាច់បង្កើនប្រវែងមុខចៀរឬចង្វាក់ចៀរណា។

## អត្ថប្រយោជន៍នៃការរំញោច

ការរំញោចនឹងជួយ ៖

- បង្កើនបរិមាណទឹកជ័រនៃអ្នកចៀរជ័រ ហើយស្របគ្នានោះប្រាក់កម្រៃរបស់អ្នកចៀរក៏កើនឡើងដែរ។
- ការចំណាយសម្បកអស់តិច។ ព្រោះហេតុនេះបានជាដើមកៅស៊ូមានរយៈពេលចៀរយកជ័របានយូរឆ្នាំ។
- បន្ថយចង្វាក់ចៀរ ប៉ុន្តែអាចយកផលបានដូចចង្វាក់ញឹក ឬ បានច្រើនជាង។ ដូចនេះ គេប្រើកម្លាំងពលកម្មតិចដែលធ្វើឱ្យសោហ៊ុយចំណាយក្នុងការប្រមូលផលថយចុះ ឯចំនួនផលនៅដដែល។
- ពន្យារការចៀរសម្បកដែលដុះថ្មីឡើងវិញ។ ដូច្នេះសម្បកដែលដុះថ្មីនេះ មានលក្ខណៈពេញលេញ ហើយមានសភាពល្អប្រសើរ។

## អំពីល្បាយថ្នាំរំញោច

សព្វថ្ងៃថ្នាំរំញោចដែលគេនិយមប្រើច្រើនជាងគេគឺ "**អេតេហ្វុន** - Ethephon" ឬ ឈ្មោះគីមីហៅថា **អាស៊ីត ២ ក្លរអេទីល - ផូស្វ៊ិក** (2 chloroethyl-phosphoric acid)។ គេអាចស្គាល់ផងដែរថ្នាំរំញោចនេះ ក្រោមឈ្មោះ "**អេត្រែល** - Ethrel" ។

អេតេហ្វុនត្រូវបានលាបក្រោមរូបភាពជាល្បាយជាមួយទឹក ឬ ប្រេង (ដូងប្រេង)។ លើទីផ្សារអាចមានល្បាយដែលមានកំហាប់ផ្សេងៗ (2,5%,5%,...)។

## ការរំញោច

ការរំញោចមានច្រើនវិធី ប៉ុន្តែវិធីដែលគេច្រើនអនុវត្តគឺវិធីលាបថ្នាំរំញោចដោយប្រើជក់លាប។

**១. វិធីលាបថ្នាំរំញោច**

នៅក្នុងចំណោមវិធីលាបទាំងឡាយ វិធីលាបនៅលើសម្បកដែលដុះឡើងវិញ (panel application) ត្រូវបានគេនិយមប្រើជាងគេ។

ក្នុងករណីនេះ ថ្នាំរំញោចត្រូវបានលាបផ្ទាល់លើមុខចៀរ (tapping cut) ទៅតាមប្រវែងមុខចៀរ (ផ្ទៃលាបមានទទឹងប្រមាណ ១សង់ទីម៉ែត្រ) នៅលើសម្បកដែលដុះឡើងវិញ។

វិធីនេះមានភាពងាយស្រួល ហើយចំណាយតិច។ ហេតុនេះហើយ វិធីនេះត្រូវបានគេអនុវត្តច្រើនជាងគេ។







**វិធីលាបលើសម្បកដែលដុះឡើងវិញ**
Panel application (Eric Gohet, 2012)

# ឯកសារបោះពុម្ពផ្សព្វផ្សាយ



















អាស័យដ្ឋានលេខ ៥៩ E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

www.crri.com.kh